00268473

ឈ១/ឈ១ ១៧/៣/៤

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត

| | |
|---|---|
| សំណុំរឿងលេខ | : ០០២/១៩-០៩-២០០៧-អវតក-កសចស |
| ដាក់ជូនទៅ | : សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទដាក់ឯកសារ | : ៣០ ធ្នូ ២០០៨ |
| ភាគីអ្នកដាក់ឯកសារ | : សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី |
| ភាសាដើម | : អង់គ្លេស និង អត្ថបទបកប្រែជាភាសាខ្មែរ |
| ប្រភេទឯកសារ | : សាធារណៈ |

---

## សារណាតបរបស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសហកម្មវត្ថុក្រិដ្ឋកម្មរួម

---

**ដាក់ជូនដោយ:**

**សហមេធាវីនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី**

លោកស្រី Silke STUDZINSKY

លោក គឹម ម៉េងឃី

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី Martine Jacquin

លោក Philippe Cannone

**ឯកសារទទួល**

DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 30 / 12 / 2008

ម៉ោង (Time/Heure): 16:00

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

CERTIFIED COPY/COPIE CERTIFIÉE CONFORME

ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 31 / 12 / 2008

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K. K. Ratanak

**ចែកចាយជូន:**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

ចៅក្រម Marcel Lemonde

ចៅក្រម យូ ប៊ុនឡេង

**សហមេធាវី របស់ អៀង សារី**

លោក អាង ឧត្តម

លោក Michael Karnavas

**សហមេធាវី របស់ អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

Diana Ellis

**សហមេធាវី របស់ ខៀវ សំផន**

លោក សា សុវណ្ណ

Jacques Verges

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William Smith

លោក Anees Ahmed

# I. សេចក្តីផ្តើម

១. ការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") បានចេញសេចក្តីអញ្ជើញ[1]ឱ្យភាគីនានាដាក់សេចក្តីសន្និដ្ឋានបន្ថែមពាក់ព័ន្ធនឹងសំណើដែលបានដាក់នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២00៨ ដោយសហមេធាវីរបស់លោក អៀង សារី ដែលស្នើថា ទស្សនាទាននៃសហកម្មឧក្រិដ្ឋកម្មរួម ("JCE") មិនត្រូវបានពិចារណាធ្វើជាទំរង់មួយនៃការទទួលខុសត្រូវ ដែលត្រូវអនុវត្តនៅមុខអវតក[2]ឡើយ។

២. ភាពអាចយកមកអនុវត្តនូវទ្រឹស្តី JCE នៅមុខអវតក ត្រូវបានពិភាក្សាពីមុនរួចមកហើយក្នុងករណីទី១ក្នុងសារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ដែលដាក់ដោយ Antonio Cassese និងអ្នកផ្សេងទៀត សាស្ត្រាចារ្យបណ្ឌិត Kai Ambos[3] និងមជ្ឈមណ្ឌលសម្រាប់សិទ្ធិមនុស្សនិង ពហុច្បាប់នៃសាកលវិទ្យាល័យ McGill[4] ។

៣. សារណារបស់សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឱ្យឆ្លើយតបចំពោះបញ្ហាគន្លឹះសំខាន់ៗដូចខាងក្រោម៖

(i) តើសហកម្មឧក្រិដ្ឋកម្មរួម មានចែងនៅក្នុងច្បាប់អ.វ.ត.ក និង/ឬ ក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦? តើសហកម្មឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទទួលខុសត្រូវ អាចយកមកអនុវត្តចំពោះមុខអ.វ.ត.កបានឬទេ?

(ii) នៅក្នុងអំឡុងពេលពាក់ព័ន្ធឆ្នាំ១៩៧៥-១៩៧៩ តើសហកម្មឧក្រិដ្ឋកម្មរួមមានចែងនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិហើយឬនៅ?

---

[1] ដីកាស្តីពីការដាក់ពាក្យនៅអវតកនៃទំរង់នៃការទទួលខុសត្រូវ ដែលត្រូវបានគេស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម។ កសចស, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២00៨, Doc. D97/III។

[2] សំណើដាក់នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២00៨ដោយសហមេធាវីរបស់ អៀង សារី ស្នើឱ្យទស្សនាទាននៃ JCE មិនត្រូវបានអនុវត្តនៅមុខអវតក , Doc. D97។ ស

[3] "បន្ទាប់មកហៅថាសារណារបស់លោក Ambos" ដែលត្រូវបានដាក់នៅលើគេហទំព័ររបស់អវតក ។

[4] "បន្ទាប់មកហៅថាសារណារបស់លោក Mc Gill" ដែលត្រូវបានដាក់នៅលើគេហទំព័ររបស់អវតក ។

00268475



(iii) តើសហកម្មឧក្រិដ្ឋកម្មរួម មានភាពស្របគ្នានឹងគោលការណ៍នីត្យានុកូលភាព គោលការណ៍គ្មានទោសប្រសិនគ្មានច្បាប់ចែងឬទេ[5]?

## II សេចក្ដីសង្ខេបនន្នីករណ៍

៤. សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មិនមានចែងនៅក្នុងមាត្រា២៩ នៃច្បាប់អ.វ.ត.ក ឬនៅក្នុងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ទេ ដូច្នេះទម្រង់នេះមិនអាចយកមកអនុវត្តបានទេ។

៥. សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា ទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មទម្រង់ទី៣ មិនអាចយកមកអនុវត្តចំពោះមុខអ.វ.ត.ក ដោយសារទ្រឹស្ដីនេះមិនមានចែងនៅក្នុងច្បាប់ទំនៀមទំលាប់ក្នុងអំឡុងពេលពាក់ព័ន្ធឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

## III. អង្គហេតុពាក់ព័ន្ធ

៦. ទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មរួមក្នុងទម្រង់នៃការទទួលខុសត្រូវ អាចរកឃើញនៅក្នុងទ្រឹស្ដីអង់គ្លេសនៃគោលបំណងរួម។ ទាំងនៅក្នុងច្បាប់ក្នុងស្រុក និងនៅក្នុងច្បាប់បរទេស ការចូលរួមប្រព្រឹត្ត(ទូទៅ) និងការចូលរួមប្រព្រឹត្តដែលពាក់ព័ន្ធគោលបំណងរួម ឬផែនការរួមមានលក្ខណៈផ្សេងគ្នា។ ភាពខុសគ្នារបស់ចំណុចទាំងពីរនេះត្រង់ថា នៅពេលការចូលរួមប្រព្រឹត្តបានបង្កើតនូវគោលបំណងរួម ហើយមានការកំណត់តួនាទីនៅក្នុងការប្រព្រឹត្តនោះ សមាជិកនីមួយៗនៃគោលបំណងរួមត្រូវទទួលខុសត្រូវស្មើៗគ្នា ដោយមិនគិតពីភាពធ្ងន់ធ្ងរនៃបទល្មើសដែលគាត់បានចូលរួម និងតួនាទីរបស់គាត់ទេ។ ផ្ទុយមកវិញ ចំពោះករណីចូលរួម

[5] គោលការណ៍នេះមានន័យថា គ្មាននរណាម្នាក់អាចត្រូវបានផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋកម្មមួយ ដែលមិនបានកំណត់ថាជាបទឧក្រិដ្ឋកម្មក្នុងច្បាប់ឡើយ។

ប្រព្រឹត្តដោយគ្មានគោលបំណងរួម ការទទួលខុសត្រូវនៃចារីនីមួយៗត្រូវបានកំណត់ដោយផ្អែកលើបទល្មើសដែលខ្លួនបានប្រព្រឹត្ត[6]។

៧. នៅក្នុងឆ្នាំ១៩៩៩ អង្គជំនុំជម្រះតុលាការកំពូល ICTY បានប្រកាសនៅក្នុង *រឿងក្តីTadic* ថា សហកម្មឧក្រិដ្ឋកម្មរួមមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[7]នៅក្នុងពេលវេលាពាក់ព័ន្ធនោះ ដូច្នេះតុលាការបានសម្រេចឲ្យសមាជិកនីមួយៗនៃ"ផែនការរួម" ទទួលខុសត្រូវស្មើៗគ្នា ដោយមិនគិតអំពីភាពធ្ងន់ធ្ងររបស់បទល្មើស ឬការចូលរួមប្រព្រឹត្តរបស់បុគ្គលនីមួយៗទេ[8]។

៨. អង្គជំនុំជម្រះតុលាការកំពូល ដោយផ្អែកស្ទើរតែទាំងស្រុងលើច្បាប់យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ បានធ្វើការវែកញែកទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួម៖

(i) ទម្រង់ជាមូលដ្ឋាន គឺជាទម្រង់ដែលអ្នកចូលរួម ប្រព្រឹត្តដោយឈរលើមូលដ្ឋាន "ផែនការរួម" ឬ"គម្រោងការណ៍រួម" និងដោយមាន"ចេតនា"រួម ("សហកម្មឧក្រិដ្ឋកម្មទម្រង់ទី១")។

(ii) ទម្រង់ជាប្រព័ន្ធ ឧទាហរណ៍ករណីនៅជំរុំឃុំឃាំង ដែលសមាជិកយោធា ឬអង្គភាពរដ្ឋបាល ដូចជាជនដែលគ្រប់គ្រងជំរុំឃុំឃាំង បានប្រព្រឹត្តបទល្មើសនានាដោយឈរលើមូលដ្ឋាន "ផែនការរួម" ឬ "គោលបំណងរួម" ("សហកម្មឧក្រិដ្ឋកម្មទម្រង់ទី២")។

(iii) "ទម្រង់ពង្រីកបន្ថែម" ដែលសហចារីម្នាក់ចូលរួមប្រព្រឹត្តសកម្មភាពលើសពីគម្រោងរួម ប៉ុន្តែសកម្មភាពរបស់ជននោះ បានត្រូវបង្កើតជា"ផលវិបាកដែលកើតឡើងដោយឯកឯង និងដែលអាចដឹងជាមុន" ក្នុងសម្រេចផែនការ ("សហកម្មឧក្រិដ្ឋកម្មទម្រង់ទី៣")។

---

[6] សូមមើល I. Bantekas and S. Nash *"ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ"* បោះពុម្ពផ្សាយលើកទីបី ផ្នែកទី២, ២.៥ ទំព័រទី២៩។

[7] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Tadic* សេចក្តីសម្រេចរបស់តុលាការកំពូល (ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩) កថាខណ្ឌទី១៩៤ និងកថាខណ្ឌបន្តបន្ទាប់។ សហកម្មឧក្រិដ្ឋកម្មរួមជាទម្រង់ទទួលខុសត្រូវ បានសម្រេចជាបន្តបន្ទាប់ដោយពិតប្រាកដចំពោះអង្គជំនុំជម្រះនានារបស់តុលាការICTY។ សូមមើល ឧទា. *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Vasiljevic* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២00២) កថាខណ្ឌទី៦៣ និងកថាខណ្ឌបន្តបន្ទាប់ទៀត។

[8] សូមមើល សាលក្រម *រឿងក្តីVasiljevic* កំណត់សម្គាល់ទី៣៨ កថាខណ្ឌទី៦៧។

៩. តុលាការផ្សេងៗបានធ្វើការសម្រេចរបស់ខ្លួន បន្ទាប់ពីមានច្បាប់យុត្តិសាស្ត្ររបស់តុលាការ ICTY និងតុលាការICTRជាបន្តបន្ទាប់[9]។ នៅក្នុងរឿងក្តីថ្មីៗនៃតុលាការកូនកាត់ ក្រុមប្រឹក្សាពិសេសរបស់ប្រទេសទីម័រខាងកើតសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ[10] កំពុងអនុវត្តនូវទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ហើយតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន(“SCSL”) ក៏កំពុងអនុវត្តទ្រឹស្តីនេះដែរ[11]។

## IV. ឧត្តរកម្ម
## សហកម្មឧក្រិដ្ឋកម្មរួម និងច្បាប់ស្តីពីការបង្កើតឲ្យមានអ.វ.ត.ក

១០. ជាដំបូង យើងត្រូវកំណត់ថាតើសហកម្មឧក្រិដ្ឋកម្មរួម មានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអ.វ.ត.កទេ។ សហកម្មឧក្រិដ្ឋកម្មរួមមិនមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអ.វ.ត.កទេ។ ច្បាប់ស្តីពីការបង្កើតឲ្យមានអ.វ.ត.ក មិនមានរួមបញ្ចូលសហកម្មឧក្រិដ្ឋកម្មក្នុងទម្រង់ទទួលខុសត្រូវច្បាស់លាស់ទេ។ មាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក[12] បានចែងអំពីការទទួលខុសត្រូវរបស់ជនសង្ស័យណាមួយ ដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអ.វ.ត.ក។

១១. ការបកស្រាយនៅក្នុង*រឿងក្តីTadic* ដែលលើកឡើងថា “ការប្រព្រឹត្តបទល្មើសមួយក្នុងចំណោមបទល្មើសនានាដែលមានចែងនៅក្នុងមាត្រា២ មាត្រា៣ មាត្រា៤ ឬមាត្រា៥នៃ

---

[9] សូមមើលឧទា. សាលដីកា*រឿងក្តីStakic*របស់អង្គជំនុំជម្រះតុលាការកំពូល *សូមមើលខាងលើ*ជើងទំព័រលេខ៥ កថាខណ្ឌទី៦៤ ទី៦៥។ សាលក្រមនិងការផ្តន្ទាទោស *Simba*របស់អង្គជំនុំជម្រះតុលាការដំបូង (សំណុំរឿងលេខ ICTR-01-76) ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២00៥ កថាខណ្ឌទី៣៨៦ ទី៣៨៨។

[10] សូមមើលសេចក្តីសម្រេច*រឿងក្តីPerreira*របស់ក្រុមប្រឹក្សាពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២00៥ នៅចំណុច១៩-២0។

[11] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Alex Tamba Brimaនិងជនផ្សេងទៀត* សំណុំរឿងលេខSCSL-2004-16-A អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២00៨។

[12] មាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ដូចគ្នានឹងមាត្រា៧(១)នៃច្បាប់លក្ខន្តិកៈរបស់តុលាការICTY។

ច្បាប់លក្ខន្តិកៈ អាចនឹងកើតឡើងតាមរយៈការចូលរួមប្រព្រឹត្តដើម្បីសម្រេចនូវគោលបំណងឬផែនការរួម"[13] គឺជាការបកស្រាយបែបទូលាយដើម្បីផ្តល់យុត្តិកម្មចំពោះទស្សនៈដែលថា ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមទាំងបី កើតចេញមកពីការ"ប្រព្រឹត្ត"ឧក្រិដ្ឋកម្ម។ ជាពិសេស ធាតុផ្សំចេតនា និងធាតុផ្សំអំពើពិរុទ្ធ មិនមានចែងទាក់ទងនឹងការទទួលខុសត្រូវជារួមនៅក្នុងច្បាប់លក្ខន្តិកៈទេ។

បើទោះជាលក្ខន្តិកៈនៃតុលាការពិសេស SCSL និង លក្ខន្តិកៈនៃតុលាការ ICTR មិនបានប្រើប្រាស់ JCE ធ្វើជាការទទួលខុសត្រូវក្តី ក៏តុលាការទាំងនេះបានប្រើប្រាស់ JCE មកពីពាក្យ "ប្រព្រឹត្ត"[14] ។

១២. សារណារបស់ McGill មិនបានលើកឡើងអំពីបញ្ហាថាតើសហកម្មឧក្រិដ្ឋកម្មរួមមានចែងនៅក្នុងច្បាប់អ.វ.ត.កទេ។ សារណារបស់ Ambos[15] បានលើកឡើងថា ធាតុផ្សំជាក់លាក់របស់សហកម្មឧក្រិដ្ឋកម្មទម្រង់ទី១ ទម្រង់ទី២ និងទម្រង់ទី៣ មិនមាននៅក្នុងច្បាប់លក្ខន្តិកៈ ប៉ុន្តែមាននៅក្នុងច្បាប់យុត្តិសាស្ត្រទំនៀមទំលាប់។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានយល់ឃើញថា ទម្រង់សហកម្មឧក្រិដ្ឋកម្មទម្រង់ទី៣ មិនអាចចេញមកពីពាក្យ"ប្រព្រឹត្តបទល្មើស"ដែលមានចែងនៅក្នុងមាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអ.វ.ត.ក ទេ។

១៣. បន្ថែមលើនេះទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងករណី Tadic បានប្រើប្រាស់មាត្រាទី១ នៃលក្ខន្តិកៈ ដើម្បីធ្វើឱ្យសមស្របនូវយុទ្ធិសាស្ត្រដែលមានលក្ខណៈកាន់តែទូលំទូលាយដោយបានសង្កត់ថា "កម្មវត្ថុ និងគោលដៅ" គឺដើម្បីកាត់ក្តីអ្នកដែលទទួលខុសត្រូវចំពោះការបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ[16]។ ភាពចាំបាច់ផ្នែកសីលធម៌ក្នុងការកាត់សេចក្តីអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់អំពើឃោរឃៅជាច្រើន មិនអាចធ្វើឱ្យត្រឹមត្រូវតាមការពង្រីកនូវ

[13] *សូមមើលខាងលើ*នៅជើងទំព័រលេខ៧ កថាខណ្ឌ១៨៨។

[14] សូមមើលមាត្រា៦(១) នៃលក្ខន្តិកៈតុលាការ ICTR និងមាត្រា៦(១)នៃលក្ខន្តិកៈតុលាការពិសេស SCSL ។

[15] សារណារបស់ Ambos II.២ ទំព័រទី២១, ទី២២។

[16] សូមមើលខាងលើនៅជើងទំព័រលេខ៧ (Tadic) កថាខណ្ឌ១៨៨ ។

លក្ខន្តិកៈអ.វ.ត.កឱ្យបានច្បាស់និងត្រង់ៗ ហើយរួមបញ្ចូលទម្រង់សហកម្មឧក្រិដ្ឋកម្មរួម *ទាំងអស់* នៅក្នុងពាក្យ“ប្រព្រឹត្ត”នោះទេ។ ទឡ្ហីករណ៍នេះបញ្ជាក់ពីការត្រឡប់សាក្រោយវិញពីសំណើដែលចុងចោទត្រូវតែផ្តន្ទាទោស។ ដោយព្រោះថាចុងចោទត្រូវតែផ្តន្ទាទោសនោះ លក្ខន្តិកៈចាំបាច់ត្រូវតែអានក្នុងរបៀបមួយដែលផ្តល់លទ្ធផលគួរឱ្យពេញចិត្ត។ ទឡ្ហីករណ៍នេះមានលក្ខណៈជារង្វង់ជុំ[17]។

ជាពិសេស សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ សម្រេចឱ្យបុគ្គលម្នាក់ទទួលខុសត្រូវចំពោះអំពើ *ដែលប្រព្រឹត្ត*ដោយបុគ្គលសហកម្មឧក្រិដ្ឋកម្មរួមផ្សេងទៀត។ ដូច្នេះ ជនទាំងឡាយដែលត្រូវបានសម្រេចឱ្យទទួលខុសត្រូវតាមរយៈទម្រង់ទី៣ មិនបាន*ប្រព្រឹត្តបទល្មើស*ដោយផ្ទាល់ទេ។

១៤. នៅពេលច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមមិនបានប្រើពាក្យ“សហកម្មឧក្រិដ្ឋកម្មរួម”ដោយផ្ទាល់ទេ ប៉ុន្តែច្បាប់នេះបានចែងយ៉ាងច្បាស់អំពីការទទួលខុសត្រូវ នៅពេលជនចូលរួមប្រព្រឹត្តបទល្មើសតាមរយៈក្រុមជនដែលប្រព្រឹត្តដោយមានគោលបំណងរួម ហើយការប្រព្រឹត្តឧក្រិដ្ឋកម្មត្រូវស្ថិតនៅក្នុងយុត្តាធិការតុលាការ។[18]

ទោះបីជាមានច្បាប់យុត្តិសាស្ត្ររបស់តុលាការICTY ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម និងមាត្រា២៥(៣)(ឃ)នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមក្នុងពេលធ្វើពង្រាងនិងអនុម័តច្បាប់ស្តីពីការបង្កើតឱ្យមានអ.វ.ត.ក ក្តី ក៏ច្បាប់នេះមិនមានចែងច្បាស់អំពីសហកម្មឧក្រិដ្ឋកម្មរួមក្នុងទម្រង់ទទួលខុសត្រូវទេ។

លើសពីនេះ ការលុបចោលសហកម្មឧក្រិដ្ឋកម្មរួមយ៉ាងច្បាស់នៅក្នុងច្បាប់អ.វ.ត.ក ធ្វើឱ្យមានការសន្និដ្ឋានថា សហកម្មឧក្រិដ្ឋកម្មរួមមិនបានរួមបញ្ចូលក្នុងទម្រង់នៃការទទួលខុសត្រូវទេ។

---

[17] J.D. Ohlin, បញ្ហាទស្សនាទានបីជាមួយនឹងទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម, Journal of International Criminal Justice 5 (2007), ទំព័រ៧២ ។

[18] មាត្រា ២៥(៣) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សេចក្តីសម្រេចលើការបញ្ជាក់បទចោទប្រកាន់ សំណុំរឿងលេខICC-01/04-01/06-803-tEN ICC Pre-Trial ChamberI ស្ថានភាពនៅក្នុងសាធារណរដ្ឋប្រជាធិតេយ្យកុងហ្គោ ថ្ងៃទី២៩ ខែមករា ឆ្នាំ២00៧ កថាខណ្ឌទី៣២៦ ដល់៣៣0 នៅពេលអង្គបុរេជំនុំជម្រះគាំទ្រទ្រឹស្តីការចូលរួមប្រព្រឹត្ត ជាជាងសហកម្មឧក្រិដ្ឋកម្មនៅក្នុងន័យមាត្រា២៥(៣)នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម។

១៥. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា សហកម្មឧក្រិដ្ឋកម្មទម្រង់ទី៣មិនអាចប្រើដោយផ្ទាល់ឬដោយប្រយោលពីមាត្រា២៩នៃច្បាប់ស្តីពីការបង្កើតឱ្យមានអ.វ.ត.កទេ។

**សហកម្មឧក្រិដ្ឋកម្មរួម និងច្បាប់ជាតិរបស់កម្ពុជាក្នុងអំឡុងពេលពាក់ព័ន្ធ**

១៦. ទោះបីជាអ.វ.ត.កមានយុត្តាធិការលើក្រមច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ក្នុងអំឡុងពេលពាក់ព័ន្ធក្តី ក៏ក្រមនេះមិនមានចែងអំពីការទទួលខុសត្រូវក្នុងទម្រង់ទី៣នៃសហកម្មឧក្រិដ្ឋកម្មរួមទេ។ សារណារបស់ McGill[19] និងសារណារបស់ Ambos[20] បានបញ្ជាក់ថាក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦មិនបានទទួលស្គាល់ទម្រង់នៃការទទួលខុសត្រូវដូចសហកម្មឧក្រិដ្ឋកម្មទម្រង់ទី៣ទេ[21]។

១៧. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របនឹងសេចក្តីសន្និដ្ឋាននេះ ដោយផ្អែកលើអង្គហេតុដែលថា មាត្រា៨២៖ការចូលរួមប្រព្រឹត្ត និងមាត្រា៨៣៖ការសមគំនិត នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងតែអំពីស្ថានភាពដែលចុងចោទចូលរួមប្រព្រឹត្តបទចូលរួមប្រព្រឹត្ត ឬក៏បទសមគំនិត។ គ្មានបទប្បញ្ញត្តិណាមួយក្នុងក្រមនេះ មានចែងអំពីការទទួលខុសត្រូវដែលស្រដៀងនឹងសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ទេ។

[19] សារណារបស់ Mc Gill កថាខណ្ឌទី៣៨-៣៩។

[20] សារណារបស់ Ambos II.៤ ទំព័រទី២៩, ទី៣០។

[21] សារណារបស់ Mc Gill កថាខណ្ឌ៣៨, ៣៩០: សារណារបស់ Ambos II.៤ ទំព័រទី២៩, ទី៣០។

00268481



## សហកម្មឧក្រិដ្ឋកម្មរួម ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលដែលពាក់ព័ន្ធ

១៨. សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា ទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួម ជាពិសេសទម្រង់ពង្រីក មិនបានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធឡើយ។ ម៉្យាងវិញទៀត សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងទម្រង់ទីពីរ អាចត្រូវបានគេចាត់ទុកដូចគ្នាដែរ។ អត្ថិភាពនៃវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិមានលក្ខខណ្ឌតម្រូវ (ក) ការអនុវត្តន៍ជាទូទៅ និងស៊ីសង្វាក់គ្នារបស់រដ្ឋ និង (ខ) *គំនិតគតិយុត្ត (opinion juris)*[22]។

១៩. ប៉ុន្តែ នៅក្នុងបរិបទនេះ គេអាចចោទជាសំណួរឡើងថាតើយុត្តិសាស្ត្ររបស់សាលាក្តីយោធាអន្តរជាតិ ជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ដែរឬទេ ពីព្រោះតែរបាយការណ៍ក្នុងឆ្នាំ១៩៩៣ របស់អគ្គលេខាធិកា ស្តីពីការបង្កើតសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ត្រូវបានគេចាត់ទុកថា ជាការបង្ហាញជាលើកដំបូងអំពីឋានៈនៃទំនៀមទម្លាប់។ គេបានលើកឡើងថា សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី "គួរអនុវត្តវិធានច្បាប់មនុស្សធម៌អន្តរជាតិ ដែលវាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ *ដោយគ្មានមន្ទិលសង្ស័យណាមួយឡើយ*[23] (...) ហើយផ្នែកនៃច្បាប់មនុស្សធម៌អន្តរជាតិមានលក្ខណៈជាទំនៀមទម្លាប់នេះ បានប្រែក្លាយជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលនៅជាធរមាននៅក្នុងជម្លោះប្រដាប់អាវុធ ដូចមានចែងនៅក្នុងធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិ(...)។[24]

---

[22] ទស្សនាវដ្តីអន្តរជាតិនៃកាកបាទក្រហម ច្បាប់ទំនៀមទម្លាប់ វ៉ុលលឹម ៨៧ លេខ ៨៥៧ ខែមីនា ឆ្នាំ២០០៥ ទំព័រទី ១៧៨។

[23] គូសបញ្ជាក់បន្ថែម។

[24] របាយការណ៍របស់អគ្គលេខាធិការ អនុលោមតាមវាក្យខណ្ឌទី ២នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ៨០៨(១៩៩៣) វាក្យខណ្ឌទី ៣៤ ដល់ វាក្យខណ្ឌទី ៣៥។

២០. គេអាចផ្តល់អំណះអំណាងនៅក្នុងន័យនេះថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃស.ក.អ.យ.វ ដែលបានបញ្ចូលទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួមនេះនៅក្នុងរឿងក្តី *Tadić* មិនបានធ្វើការវិភាគឱ្យបានហ្មត់ចត់អំពីការអនុវត្តរបស់រដ្ឋ ឬក៏*គំនិតគតិយុត្ត*។

២១. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការICTY បានបង្ហាញនៅក្នុងរឿងក្តី *Tadić* ថា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ និងទីពីរ យ៉ាងហោចណាស់ គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ប៉ុន្តែ ចំពោះសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីបីវិញ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ខកខានមិន បានធ្វើ ការសន្និដ្ឋានឱ្យរឹងមាំ និងស្រដៀងគ្នា ដោយសារតែផលវិបាកនៃឧទាហរណ៍ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ចង្អុលយោង។ ការដកស្រង់រឿងក្តីនៃអំពើហិង្សារបស់ក្រុមជនឥតសណ្តាប់ធ្នាប់ បានឆ្លុះបញ្ចាំងខ្លាំងលើសហកម្មឧក្រិដ្ឋកម្មទម្រង់ទីមួយ ជាពិសេសគឺ ចារីមានគម្រោងរួម(កើតឡើងដោយឯកឯង) ហើយក្រោយមក ចូលរួមប្រព្រឹត្តតាមរយៈអំពើនៃការសម្លាប់ខុសៗគ្នា។

២២. សារណារបស់ Mc Gill សន្និដ្ឋានថា យុត្តិសាស្ត្ររបស់សង្គ្រាមលោកលើកទីពីរ បានលើកឡើងនៅក្នុងរឿងក្តីរបស់ *Tadić* មិនសូវជារឹងមាំឡើយ ហើយសារណានេះកត់សម្គាល់ឃើញថា រឿងក្តី *Essen Lynching* និង *Borkum* មិនសូវជាបង្ហាញច្បាស់អំពីតួនាទី ឬចេតនារបស់អ្នកចូលរួមប្រព្រឹត្តនីមួយៗ។ ហេតុដូច្នេះ រឿងក្តីទាំងពីរនេះត្រូវបានគេទាញការសន្និដ្ឋានចេញពីអំណះអំណាងរបស់អយ្យការ និងពីការរកឃើញអំពីពិរុទ្ធភាព នៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធី។[25]

២៣. សារណារបស់ Ambos សន្និដ្ឋានថា រឿងក្តីសង្គ្រាមលោកលើកទីពីរដែលគេចង្អុលយោងនៅក្នុងរឿងក្តីរបស់ *Tadić* ដើម្បីផ្តល់ជាទឡ្ហីករណ៍គាំទ្រថា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីបីត្រូវ

---

[25] សារណារបស់ Mc Gill កថាខណ្ឌទី១៥ និង កថាខណ្ឌទី ២៣ ដល់កថាខណ្ឌទី ២៤។

បានរឿងក្តីសង្គ្រាមលោកលើកទីពីរទទួលស្គាល់នោះ, មិនបានបង្ហាញថា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីបីនេះ ត្រូវបានគេយកមកអនុវត្តនោះទេ។[26]
សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា នៅក្នុងរឿងក្តីទាំងពីរ ចុងចោទមានវត្តមាន ឬក៏នៅកៀកនឹងទីកន្លែងដែលឃាតកម្មទាំងឡាយបានកើតឡើងតែម្តង ហើយចុងចោទទាំងអស់នេះមិនត្រូវបានគេចោទប្រកាន់ថាបានពាក់ព័ន្ធក្នុងការចូលរួមនៅក្នុងផែនការណ៍ដែលមានលក្ខណៈធំធេងហួសពីការប្រព្រឹត្តខុសច្បាប់លើអ្នកទោសឡើយ។

២៤. មិនតែប៉ុណ្ណោះ យើងមិនឃើញមានអត្ថិភាពនៃការអនុវត្តជារួមរបស់រដ្ឋ។ ឧទាហរណ៍ ប្រទេសអាល្លឺម៉ង់ ប្រទេសហូឡង់ដ៍ និងប្រទេសស្វីស មិនបានយកទម្រង់នៃការទទួលខុសត្រូវបែបនេះ ទៅបញ្ចូលនៅក្នុងក្រមព្រហ្មទណ្ឌរបស់ខ្លួនឡើយ។ ប៉ុន្តែ នៅក្នុងប្រទេសដទៃៗវិញ ដូចជា ចក្រភពអង់គ្លេស ប្រទេសកាណាដា សហរដ្ឋអាមេរិក ដែលបានបញ្ចូលទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលអាចប្រមើលមើលឃើញ ប៉ុន្តែមិនមានបំណង, បានធ្វើឱ្យគេរិះគន់យ៉ាងចាស់ដៃចំពោះទ្រឹស្តីនេះ[27]។

២៥. ការចង្អុលយោងលើករណីនៃប្រទេសអ៊ីតាលី[28] ក៏មានលក្ខណៈស្រដៀងគ្នាដែរ ដែលមិនមានជាឧទាហរណ៍ដែលចង្អុលបង្ហាញដើម្បីបង្កើតសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីបីឡើយ ដោយសារតែលក្ខខណ្ឌតម្រូវនៃចេតនាឧក្រិដ្ឋមិនត្រូវបានលើកឡើងឱ្យបានច្បាស់លាស់ ហើយចារីមិនត្រូវបានចាប់ឱ្យទទួលខុសត្រូវ ក្នុងករណីដែល"ការសម្លាប់គឺជាព្រឹត្តិហេតុពិសេស ហើយមិនត្រូវបានគេប្រមើលមើលឃើញ"[29]។

[26] សារណារបស់ Ambos II.៣.៣. កថាខណ្ឌទី ២៨ ដល់កថាខណ្ឌទី ២៩។ សូមអានផងដែរ Allison Marston Danner និង Jenny S. Martinez សមាគមន៍ឧក្រិដ្ឋ: សហកម្មឧក្រិដ្ឋកម្មរួម, ការទទួលខុសត្រូវរបស់ថ្នាក់លើ និង ការវិវឌ្ឍន៍នៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (២០០៤) សាកលវិទ្យាល័យច្បាប់នៃ Vanderbilt ឯកសារស្រាវជ្រាវ លេខ ៨៧ កថាខណ្ឌទី ៣៨ ដល់ កថាខណ្ឌទី ៤០។

[27] សូមអានសារណារបស់ Mc Gill កថាខណ្ឌទី ៣៥, កថាខណ្ឌទី ៣៦។ សូមអាន Allison, ជើងទំព័រទី៦ ខាងលើ, កថាខណ្ឌទី ៣២។

[28] សូមអានជើងទំព័រទី៧ ខាងលើ, កថាខណ្ឌទី ២១៥ ដល់កថាខណ្ឌទី ២១៩។

[29] សូមអានជើងទំព័រទី៧ ខាងលើ, កថាខណ្ឌទី ២១៧។

00268484



២៦. យើងអាចសន្និដ្ឋានថា ឧទាហរណ៍ដែលបានចង្អុលយោងនៅក្នុងរឿងក្ដី Tadić មិនបានបង្កើតជាករណីថា តាមយុត្តិសាស្ត្រជាតិ ឬយុត្តិសាស្ត្រអន្តរជាតិសហាកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីបីគឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ សហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក៏អះអាងដូចគ្នាដែរ។
មិនថាតាមរយៈយុត្តិសាស្ត្រពីមុន ឬការអនុវត្តន៍របស់រដ្ឋ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្ដី Tadić ខកខានមិនបានបង្ហាញអំពីអត្ថិភាពនៃសហាកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីបីថាជា "ច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។

## អនុសញ្ញាអន្តរជាតិ និងសហាកម្មឧក្រិដ្ឋកម្មរួម

២៧. បញ្ហាចោទមួយទៀតដែលត្រូវយកមកពិចារណាគឺថាតើ តាំងមុនមក ទ្រឹស្ដីសហាកម្មឧក្រិដ្ឋកម្មរួមនេះត្រូវបានទទួលស្គាល់ដោយអនុសញ្ញាអន្តរជាតិដែរឬទេ ដែលហេតុដូច្នេះហើយបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

២៨. សន្ធិសញ្ញាអន្តរជាតិដែលបានលើកឡើងនៅក្នុងរឿងក្ដី Tadić[30] រួមមានដូចជាអនុសញ្ញាស្ដីពីការបង្ក្រាបការទម្លាក់គ្រាប់បែករបស់ភេរវករ និងលក្ខន្តិកៈទីក្រុងរ៉ូម មិនជាប់ពាក់ព័ន្ធចំពោះអំឡុងពេលដែលពាក់ព័ន្ធនេះទេ គឺអំឡុងពេលចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។
ដូច្នេះ នៅក្នុងអំឡុងពេលនេះ មិនមានអនុសញ្ញា ឬសន្ធិសញ្ញាណាមួយដែលមានស្រាប់ ហើយគាំទ្រដល់ទ្រឹស្ដីសហាកម្មឧក្រិដ្ឋកម្មរួមនេះឡើយ។

[30] សូមអានជើងទំព័រទី៧ ខាងលើ, វាក្យខណ្ឌទី ២២១។

00268485



## គោលការណ៍នីត្យានុកូលភាព

២៩. ច្បាប់អ.វ.ត.ក បានរួមបញ្ចូលបទប្បញ្ញត្តិនៅក្នុងមាត្រា ៣៣ ថ្មី ដោយយោងលើមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(“កសអពន”) ដែលចែងថា:

> “គ្មានជនណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្ត នោះឡើយ។ ដូចគ្នានេះ មិនត្រូវដាក់ទោសឱ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើស ឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឱ្យមានការដាក់ទោសស្រាល ជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។”

៣០. គេត្រូវតែគូសបញ្ជាក់ថា គោលការណ៍នេះត្រូវបានទទួលស្គាល់ដោយច្បាប់ជាតិ និងអន្តរជាតិ ហើយចងកាតព្វកិច្ចដល់ព្រះរាជាណាចក្រកម្ពុជា ដោយសារព្រះរាជាណាចក្រកម្ពុជាគឺជារដ្ឋភាគីនៃសិទ្ធិសញ្ញា ដែលបានផ្តល់សច្ចាប័ននៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២[31]។

៣១. *គោលការណ៍នីត្យានុកូលភាព* - ជា *គោលការណ៍យុត្តិធម៌* - ចែងថា ឧក្រិដ្ឋកម្ម *និងទម្រង់នៃការទទួលខុសត្រូវ* ដែលដាក់បន្ទុកលើចុងចោទ ត្រូវតែមានអត្ថិភាព ហើយអាចប្រមើលមើលឃើញ នៅពេលដែលឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់ បានប្រព្រឹត្តឡើង[32]។ ដោយសារតែមិនមានការបង្កើតឡើងថា សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីបី មានអត្ថិភាពនៅក្នុងច្បាប់ជាតិ ហើយមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥, ការអនុវត្តន៍គោលការណ៍ប្រតិសកម្ម គឺជាការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព។

៣២. នៅពេលពិចារណាវិសាលភាពនៃមាត្រា ២៩ នៃច្បាប់អ.វ.ត.ក ក្នុងលក្ខណៈទូលាយ ការរះគន់យ៉ាងធ្ងន់ធ្ងរ[33] ចំពោះទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួម(ទម្រង់ទីបី) នៅតែមាននៅឡើយ

---

[31] ប្រទេសកម្ពុជាចុះហត្ថលេខាលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០។

[32] គោលការណ៍ *គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* រួមមានគោលការណ៍៤គឺ: lex scripta, lex certa, lex stricta, និង lex praevia។

[33] សូមអានសេចក្តីសង្ខេបនៅក្នុង A. Cassese “*ដែនកំណត់សមស្របនៃការទទួលខុសត្រូវរបស់បុគ្គល អនុលោមតាមទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម*” ទិនានុប្បវត្តិនៃតុលាការយុត្តិធម៌អន្តរជាតិ លេខ ៥ (២00៧) ទំព័រលេខ (១0៩-១៣៣), ទំព័រ ១១៤-១១៦។ Elies van Sliedregt “សហកម្មឧក្រិដ្ឋកម្ម

ហើយមិនមានមូលដ្ឋានសម្អាងហេតុណាមួយសមហេតុផល ក្នុងការចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីបីថាជា ច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ នៅក្នុងអំឡុងពេលចាប់ពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៩។

៣៣. ដូច្នេះ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របជាមួយនឹងការរិះគន់ ចំពោះយុត្តិសាស្ត្ររបស់សហរដ្ឋអាមេរិក ដែលបានលើកឡើងខាងលើ ដូចមាននៅក្នុងសារណារបស់សាកលវិទ្យាល័យ McGill នៅក្នុងវាក្យខណ្ឌទី ៣៥ ដល់ វាក្យខណ្ឌទី ៣៧, និងចំពោះយុត្តិសាស្ត្ររបស់តុលាការជាតិ និងអន្តរជាតិ ព្រមទាំងអ្នកប្រាជ្ញាជាតិនិងអន្តរជាតិវាក្យខណ្ឌទី ៤១ ដល់ វាក្យខណ្ឌទី ៥៣ ។ វិសាលភាពធំធេងនៃមតិរិះគន់នៅក្នុងតុលាការជាតិ ឬអន្តរជាតិ បានបង្ហាញស្រាប់ហើយថា ក្នុងកម្រិតមួយទូលំទូលាយបំផុតនោះ សហកម្មឧក្រិដ្ឋកម្មរួមគឺនៅមានមតិជំទាស់គ្នាយ៉ាងខ្លាំងនៅឡើយ។

## V. **សេចក្តីសន្និដ្ឋាន**

៣៤. ដើម្បីគាំទ្រដល់សារណារបស់ Ambos និងផ្នែកមួយចំនួននៃសារណារបស់ McGill, សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថា សហកម្មឧក្រិដ្ឋកម្មទម្រង់ទីបី មិនអនុវត្តបានឡើយ នៅចំពោះមុខ អ.វ.ត.ក ដោយសារតែទម្រង់នេះមិនមានចងក្រងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ និង ច្បាប់អ.វ.ត.ក។ ហើយទម្រង់នេះមិនអាចចាត់ទុកថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនេះ គឺចន្លោះឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩។ ការអនុវត្តន៍សហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទីបីនៅ អ.វ.ត.ក នឹងបង្កើតជាការរំលោភបំពានលើគោលការណ៍ *គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង*[34]។

រួមធ្វើជាមធ្យោបាយក្នុងការផ្តោលទោសបុគ្គលនានាចំពោះអំពើប្រល័យពូជសាសន៍” ព្រឹត្តិប័ត្រយុត្តិធម៌អន្តរជាតិ (២០០៦) ទំព័រ៤-៨ ដែលភាពចម្រុងចម្រាសលើបញ្ហាវិសាលភាព, លក្ខណៈ និង ភាពដែលអាចយកមកអនុវត្តបានត្រូវបានយកមកពិភាក្សា។

[34] សូមមើលជើងទំព័រលេខ៥។

ដាក់ជូនដោយគោរពពីសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី

Silke Studzinsky
មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី

គីម ម៉េងឃី
មេធាវីមកពី avocats sans frontières

ម៉ុច សុវណ្ណារី
មេធាវីមកពី avocats sans frontières

Martine Jacquin
មេធាវីមកពី avocats sans frontières

Philippe Canonne
មេធាវីមកពី avocats sans frontières

ចុះហត្ថលេខានៅទីក្រុងភ្នំពេញ, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨